ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខៈ ០៧៦១ កស.សស /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៤

# សេចក្ដីសម្រេច
## ស្ដីពី
## ការផ្លាស់ប្ដូរ និងបន្ថែមសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សម្រាប់ជួយគាំទ្រការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

## គណៈកម្មាធិការជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញសេចក្ដីសម្រេចលេខ ១២សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្ដីសម្រេចលេខ ០៣៧សសរ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្ដីពីការបង្កើតក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងសម្រាប់ជួយគាំទ្រដល់ការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- យោងលិខិតលេខ១៨៣ មស.រប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ០១១៦ រថ.រប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងរ៉ែ និងថាមពល
- យោងលិខិតលេខ២៧០៦ ដនស/បុ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងលិខិតលេខ៤០៦ ធត ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងលិខិតលេខ៤៧២៧ កសក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការ១.-**

ត្រូវបានផ្លាស់ប្ដូរសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងចំនួន៣រូប ដូចមានរាយនាមខាងក្រោម៖

១. ឯកឧត្តម **ឆេង ឆន** អនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង ជំនួសឯកឧត្តម **រត្ន័ សារិន**

២. លោក **ភុក រស់** ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង ជំនួសលោក **ម៉ុក គុណាឧត្តម**

៣. លោក **ចឹក ឈាន់** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង ជំនួសលោក **ខឹម ចិន្តា**។

**ប្រការ២.-**

ត្រូវបានបន្ថែមសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងចំនួន៣រូប ដូចមានរាយនាមខាងក្រោម៖

១. ឯកឧត្តម **ម៉ូល ពីឌូ** រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ ជាសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង

២. ឯកឧត្តម **ឌុច សុន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ជាសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង

៣. លោក **អ៊ឹង ឌីម៉ូឡា** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងរ៉ែ និងថាមពល ជាសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង។

**ប្រការ៣.-**

សមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងដែលមានរាយនាមក្នុងប្រការ១ និងប្រការ២ខាងលើ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ច ដូចដែលមានចែងនៅក្នុងសេចក្ដីសម្រេចលេខ ០៣៧សសរ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្ដីពីការបង្កើតក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សម្រាប់ជួយគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

គ្រប់ក្រសួង ស្ថាប័នជាសមាជិកគ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋានគ.ជ.អ.ប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

**កន្លែងទទួល**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងរ៉ែ និងថាមពល
  (ដើម្បីជូនជ្រាប)
- ដូចប្រការ៤
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ